# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ វិវាទដែលនាំឲ្យជាតិបែកបាក់គ្នា ត្រូវប្រើរូបមន្តផ្សះផ្សា ។

Website: www.hoksavann.org

ថ្ងៃទី១ មីនា ២០១០



យើងនៅចាំបានថ្ងៃទី២៣ តុលា ១៩៩១, មានកិច្ចព្រមព្រៀងមួយនៅទីក្រុងប៉ារីសប្រទេសបារាំង រវាងខ្មែរទាំងបួនក្រុមបញ្ឈប់វិវាទគ្នាដោយប្រើអាវុធ, សុខចិត្តដោះស្រាយតាមផ្លូវនយោបាយដោយសន្តិវិធី ក្រោមកិច្ចឧបត្ថម្ភនៃអង្គការសហប្រជាជាតិ ។ បើគ្មានការព្រមព្រៀងគ្នាពេលនោះទេ ខ្មែរនិងខ្មែរនឹងបន្តសម្លាប់គ្នាគ្មានទីបញ្ចប់ ។

យ៉ាងណាមិញ ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ ការវិវាទគ្នារវាងគណបក្សកាន់អំណាចនិងគណបក្សប្រឆាំងមានភាពតានតឹងកាន់តែខ្លាំងឡើង ដែលធ្វើឲ្យប្រជាពលរដ្ឋខ្មែរស្លុតត្រង់និងមតិអន្តរជាតិ មានការព្រួយបារម្ភយ៉ាងខ្លាំង ព្រោះចេះតែមានរឿងរ៉ាវជាប់មិនដាច់ ។ តើនេះជាចរិតរបស់អ្នកដឹកនាំខ្មែរ ដែលចូលចិត្តតែមានការវិវាទគ្នាបែបនេះឬ ? ។

នៅសម័យមហានគរ ខ្មែរជាមហាអំណាច សម័យក្រោយមក ខ្មែរចេះតែទាស់គ្នា ដណ្តើមអំណាចគ្នា បែកបាក់ផ្ទៃក្នុង ធ្វើឲ្យទឹកដីខ្មែរដ៏ធំទូលំទូលាយនៅរួញតូចដូចសព្វថ្ងៃ ដោយសារសៀមនិងយួនរំលោភយក ។ មានពាក្យខ្មែរមួយឃ្លាពោលថា «ខ្មែរខ្ពស់កប់ពពកមកជ្រកអាចម៍ជន្លេន», «ចាមមួយចំអាមទល់មេឃ», «មនយកមេឃមកទ្រាប់អង្គុយ» ។ យើងមិនវែកញែកពាក្យទាំងអស់នេះទេ គ្រាន់តែធ្វើការកត់សម្គាល់ថា ចាមនិងមនត្រូវអស់ទឹកដី ឯខ្មែរនៅសល់តែមួយក្រវិចតូច ។ ទឹកដីខ្មែរដែលនៅសល់នេះ នឹងត្រូវបាត់បង់តទៅទៀត បើនៅតែបញ្ចេញចង្កូមដាក់គ្នា ម្នាក់ៗអួតអាងកប់ពពកគ្មាននរណាដល់ ។

យើងធ្វើការកត់សម្គាល់ថា គណបក្សកាន់អំណាចនិងគណបក្សប្រឆាំង ហាក់ដូចជាពោលសំអាងដូចគ្នា នូវផែនទីខ្នាត ១/១០០,០០០ ដែលធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ១៩៦៣-១៩៦៩ ដែលមានចែងក្នុងមាត្រា២នៃរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ខុសគ្នាតែត្រង់បច្ចេកទេសវាស់ប៉ុណ្ណោះ ។ គណបក្សកាន់អំណាចចោទគណបក្សប្រឆាំងថា គូសផែនទីក្លែងក្លាយ ។ ឯគណបក្សប្រឆាំងចោទវិញថា ការកំណត់បង្គោលព្រំដែនរវាងខ្មែរនិងវៀតណាមរបស់រាជរដ្ឋាភិបាលធ្វើឲ្យខ្មែរបាត់បង់ដី ដោយសារសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ។

តើខ្មែរនិងខ្មែរសុខចិត្តអង្គុយទល់មុខគ្នា យកផែនទីដែលសំអាងថាត្រឹមត្រូវរៀងៗខ្លួន យកមកពិភាក្សាជាមួយអ្នកបច្ចេកទេសទាំងសងខាង ឬបន្ថែមអ្នកបច្ចេកទេសទី៣ តើបច្ចេកទេសណាត្រឹមត្រូវ គប្បីយកតាមបច្ចេកទេសនោះ មិនត្រូវចោទគ្នាទៅវិញទៅមកឡើយ ។ ការប្តឹងគណបក្សប្រឆាំងដែលធ្វើឡើងដោយគណបក្សកាន់អំណាច ជាទង្វើអាក្រក់ណាស់ចំពោះតុលាការដែលអន្តរជាតិចោទថា ជាតុលាការគ្មានយុត្តិធម៌ គ្មានឯករាជ្យ ហើយជាទង្វើធ្វើឲ្យវិបត្តិនេះកាន់តែកើតធ្ងន់ឡើង ។

បញ្ហានេះគួរមានប្រតិកម្មពីវៀតណាម តែបែរជាខ្មែរគ្នាឯងដែលសុទ្ធតែអះអាងថាការពារទឹកដី ទាស់គ្នាទៅវិញ ធ្វើឲ្យវៀតណាមអង្គុយសើច ដោយគេពុំចាំបាច់មានប្រតិកម្មអ្វីខ្លាំងក្លាទេ ព្រោះខ្មែរគ្នាវាកំពុងទាស់គ្នាដោយភាពល្ងង់ខ្លៅ ។ ការចោទគណបក្សប្រឆាំងដែលខ្លាចបាត់បង់ទឹកដីទៅយួន ថាក្បត់ជាតិ មិនសមហេតុផលទេ ។ មួយទៀត ការចោទគណបក្សប្រឆាំងថា ខ្មែរកំពុងមានបញ្ហាជាមួយថៃ ទៅបំបែកកម្លាំងបង្កើតជាបញ្ហាជាមួយវៀតណាមអំពីបញ្ហាបង្គោលព្រំដែននេះ ថាជាជនក្បត់ជាតិ រឹតតែមិនសមហេតុសមផលទៅទៀត ព្រោះគណបក្សប្រឆាំងមានមុខងារពិនិត្យតាមដានមើលសកម្មភាពរបស់រាជរដ្ឋាភិបាល តើការបោះបង្គោលព្រំដែននោះត្រឹមត្រូវឬទេ ព្រោះឃើញបង្គោលតម្រុយលេខ១៨៥ បោះចូលមកដីស្រែរបស់កសិករខ្មែរជ្រៅណាស់ ។ នេះជារឿងធម្មតា មិនគួររាជរដ្ឋាភិបាលប្រើវិធានការខ្លាំងជ្រុល រហូតមានការដាក់ពាក្យប្តឹងដូចនេះឡើយ ។

ទង្វើនេះគ្មានចំណេញអ្វីមកខ្មែរទេ ផ្ទុយទៅវិញធ្វើឲ្យខ្មែរបែកបាក់គ្នាកាន់តែខ្លាំងឡើង ។ ទឹកដីជាទឹកដីខ្មែរទាំងអស់គ្នា ពុំមែនជាទឹកដីរបស់គណបក្សណាមួយទេ ត្រូវតែរួមយោបល់គ្នាការពារទឹកដីឲ្យគង់វង់ កុំឲ្យចោរសៀមចោរយួនរំលោភយកបានទៀត ។ រាជរដ្ឋាភិបាលខ្មែរឲ្យតម្លៃខ្លួនឯងខ្លាំងពេក ថាខ្លួនធ្វើអ្វីមិនខុស បានជាមិនព្រមយកយោបល់គេមកពិចារណា រហូតដាក់ពាក្យប្តឹងគេទៀត ។

តទៅនេះ យើងសូមលើកយកវិធានការរបស់ព្រះពុទ្ធដែលរំងាប់អធិករណ៍ (ជម្លោះ) រវាងព្រះសង្ឃនិងព្រះសង្ឃដោយការផ្សះផ្សាគ្នា ។ ការដែលព្រះពុទ្ធបានអនុញ្ញាតឲ្យរំងាប់អធិករណ៍ដោយការផ្សះផ្សាគ្នានេះ ដោយមានរឿងរ៉ាវដែលភិក្ខុសង្ឃទាស់ទែងខ្វែងគំនិតគ្នា ជិតបែកសាមគ្គីគ្នាជាពីរពួក ឥឡូវនឹងគាស់កកាយឲ្យកំហុសដោយចោទអាបត្តិគ្នាទៅវិញទៅមក ដោយចំឈ្មោះអាបត្តិឬចំឈ្មោះភិក្ខុនឹងនាំឲ្យបែកបាក់គ្នាកាន់តែខ្លាំងឡើង ទើបព្រះពុទ្ធអនុញ្ញាតឲ្យសង្ឃធ្វើកម្មលក្ខណៈ សូត្រ

ញត្តិទុតិយកម្មវាចា ដើម្បីរំងាប់អធិករណ៍ដោយតិណវត្ថារកៈ ។ ពាក្យថា តិណវត្ថារកៈ គឺការរំងាប់អធិករណ៍ដោយពុំចាំបាច់វែកញែកឲ្យខុសឲ្យត្រូវខាងណា នាំឲ្យអាក់អន់ចិត្តបែកសាមគ្គីគ្នា ត្រូវបំបិទមិននិយាយ ប្រៀបដូចជាយកស្មៅទៅគ្របលើលាមកកុំឲ្យធុំក្លិនពេក ។ ញត្តិទុតិយកម្មវាចានោះ គឺសង្ឃទាំងពីរពួកដែលបំរុងនឹងបែកគ្នានោះ សំដែងអាបត្តិរួមគ្នាទាំងពីរពួក ដោយសូត្រញត្តិរួមគ្នាម្តង រួចហើយសង្ឃទាំងពីរពួក ត្រូវសូត្រញត្តិម្តងមួយក្រុមៗទៀត រួមសូត្រញត្តិបីដង ។ ព្រះពុទ្ធបានអនុញ្ញាតឲ្យព្រះសង្ឃអនុវត្តតាមបែបរំងាប់អធិករណ៍ដោយតិណវត្ថារកៈនេះ អាចរួចចាកអាបត្តិទាំងអស់ វៀរលែងតែអាបត្តិសង្ឃាទិសេសនិងបារាជិក ហើយព្រះសង្ឃក៏មិនបែកគ្នាឡើយ ។

នេះជាមេរៀនដែលព្រះពុទ្ធបានអនុញ្ញាតឲ្យរំងាប់ជម្លោះរបស់ព្រះសង្ឃ ដោយការផ្សះផ្សា ដោយមិនចោទគ្នាទៅវិញទៅមក ព្រោះការពារកុំឲ្យព្រះសង្ឃបែកបាក់គ្នា ។ បើគណបក្សនយោបាយខ្មែរអនុវត្តតាមវិធានការរបស់ព្រះពុទ្ធនេះ នឹងទទួលការកោតសរសើរពីគ្រប់មជ្ឈដ្ឋាន ថាជាអ្នកចាស់ទុំនយោបាយ ។៚

❈ ❈

❈